**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខ:០២៥/០៩ រប.កកចយ

## របាយការណ៍ស្តីពីសកម្មភាពការងារប្រាំបួនខែ ឆ្នាំ ២០០៩របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងរយៈពេលប្រាំបួនខែ ឆ្នាំ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយមានអគ្គលេខាធិការដ្ឋានជាសេនាធិការ បានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

### ១-លទ្ធផលសម្រេចបាន

### ក.ការពង្រឹងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

-បានកែសម្រួលរចនាសម្ព័ន្ធដឹកនាំ គ្រប់គ្រងរបស់ក្រុមប្រឹក្សាតាមរយៈ ១-ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៨៨ ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួល មាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ២-អនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៣-ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៩/៧៦០ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ តែងតាំងសមាសភាព ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៤-ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៧៦៩ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៩ តែងតាំងសមាសភាពនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ចំនួន១២ រូប

-បានសិក្សាប្រជុំរៀបចំផែនការយុទ្ធសាស្រ្ត របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានប្រជុំផ្ទៃក្នុងរៀងរាល់ពីរសប្តាហ៍ម្តង ដើម្បីពិនិត្យពិភាក្សាលើការងារដែលអនុវត្តបាន

-បានសិក្សារៀបចំកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សម្រាប់បញ្ចូលទៅក្នុងផែនការសកម្មភាពអភិបាលកិច្ច ទី៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០០១៣

-បានប្រជុំជាទៀងទាត់រៀងរាល់ពីរខែម្តងនូវក្រុមការងារបច្ចេកទេសចម្រុះកំណែច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានធ្វើការបណ្តុះបណ្តាលជូនមន្ត្រីរបស់អគ្គលេខធិការដ្ឋាន:

-បានបញ្ជូនមន្ត្រី១រូបទៅចូលរួមសិក្ខាសាលារយៈពេលខ្លីនៅប្រទេសម៉ាឡេស៊ីស្តីពី Monitoring and Evaluation ODA Project កាលពីថ្ងៃទី៣-៥ ខែកុម្ភៈ ឆ្នាំ២០០៩

-បានបញ្ជូនមន្ត្រីចំនួន ០៩ នាក់ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលភាសារអង់គ្លេសនៅសាលា ELT

-បានបញ្ជូនមន្ត្រី ១រូប ដើម្បីទៅបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិតផ្នែកច្បាប់ និងសេដ្ឋកិច្ចអន្តរជាតិនៅប្រទេស ជប៉ុន រយៈពេល១ឆ្នាំ

-បានបញ្ជូនមន្ត្រី១ រូបទៅចូលរួមសិក្ខាសាលារយៈពេលខ្លីនៅប្រទេសសង្ហបូរីរយៈពេល ២ សប្តាហ៍ ស្តីពីកាដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

-បានបញ្ជូនមន្ត្រីចំនួន ០៤ រូបទៅចូលរួមវគ្គបណ្តុះបណ្តាលអ្នកដឹកនាំវ័យក្មេងនៅប្រទេសជប៉ុន ចំនួន១៨ ថ្ងៃ ស្តីពីអភិបាលកិច្ចល្អ និងការងារកំណែទម្រង់ច្បាប់ និងតុលាការ

-បានរៀបចំនិងបោះពុម្ភចែកផ្សាយនូវព្រឹត្តប័ត្រកំណែទម្រង់ច្បាប់ និងតុលាការខែកក្កដា ឆ្នាំ២០០៩

## ខ.ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៖

-បានប្រជុំពិនិត្យជំរុញការអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា

-បានប្រជុំរៀបចំនិងអនុម័តផែនការយុទ្ធសាស្ត្រសម្រាប់តុលាការគំរូទាំង៤គឺៈ តុលាការរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តបន្ទាយមានជ័យ

-បានរៀបចំផែនការសកម្មភាព និងផែនការថវិការបស់តុលាការគំរូទាំងបួនដាក់ជូនក្រសួងយុត្តិធម៌ ដើម្បីស្នើសុំថវិកាទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានធ្វើការសិក្សាស្ទង់មតិស្តីពីការពង្រឹងសមត្ថភាពតាក់តែងច្បាប់នៅតាមក្រសួងស្ថាប័នរដ្ឋ

-បានធ្វើការសិក្សាវាយតម្លៃបឋមអំពីការអនុវត្តប្រព័ន្ធទទួលពាក្យបណ្តឹង (Ombudsman) នៅកម្ពុជា និងបានទៅធ្វើទស្សនៈកិច្ចសិក្សាស្វែងយល់ពីប្រព័ន្ធអំប៊ូស្មាន នៅសាធារណៈរដ្ឋកូរ៉េខាងត្បូង រយៈពេលបីថ្ងៃ

-បានប្រជុំដោះស្រាយបញ្ហាប្រឈមក្នុងតុលាការ និងសិក្សារៀបចំដាក់ចេញនូវអនុក្រឹត្យលេខ ១៦០ អនក្រ ចុះថ្ងៃទី២៣ ខែ កញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើនប្រសិទ្ធភាពក្រុមប្រឹក្សាវិន័យនៃអង្គចៅក្រម

-បាននិងកំពុងសិក្សារៀបចំរដ្ឋបាលតុលាការនៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់

-បានសិក្សារៀបចំគម្រោង សម្រាប់អនុវត្តប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បាននិងកំពុងសិក្សារៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ជំនួយផ្នែកច្បាប់

-បានរៀបចំវេទិកាផ្លាស់ប្តូរយោបល់រវាងភ្នាក់ងារអនុវត្តនិងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការ រយៈពេលពីរ ថ្ងៃនៅខេត្តបន្ទាយមានជ័យ

-បានបោះពុម្ភផ្សាយឯកសារស្តីពី “មគ្គុទេសក៍ធ្វើផែនការសម្រាប់ស្ថាប័នវិស័យយុត្តិធម៌” និងធ្វើការបណ្តុះបណ្តាលជូន មន្ត្រីបង្គោល

## គ. ផ្សេងៗ

- ចូលរួមប្រជុំអន្តរក្រសួងផ្សេងៗ

-ចូលរួមសិក្ខាសាលាជាតិ ស្តីពីការផ្សព្វផ្សាយទិសដៅយុទ្ធសាស្ត្រនៃកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាល និង ការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០០៩-២០១៣ នៅថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ សណ្ឋាគារអាំងទែរ កុងទីណង់តាល់។

-ចូលរួមសិក្ខាសលាជាតិស្តីពីការផ្សព្វផ្សាយទិសដៅយុទ្ធសាស្ត្រនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល និងការរៀបចំ ផែនការសកម្មភាពសម្រាប់ឆ្នាំ២០០៩-២០០១៣ នៅថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ នៅសណ្ឋាគារ អាំងទែរកុងទី ណង់តាល់។

-បានចូរួមប្រជុំក្នុងអង្គសិក្ខសាលា ក្នុងពិធីប្រកាសផ្សព្វផ្សាយសារាចរ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលរៀចំដោយក្រសួងផែនការ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។

-ចូលរួមក្នុងប្រជុំ ជាមួយគណៈប្រតិភូធនាគាពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើៈ១-

សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ២-កំណែទម្រង់រដ្ឋបាលសាធារណៈ ៣-អភិបាលកិច្ចល្អ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង១៦ៈ០០ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យវឌ្ឍនភាពនៃប្រព័ន្ធក្រុមការងារបច្ចេកទេសចម្រុះ កាលពីថ្ងៃទី១៣-១៤ ខែសីហា ឆ្នាំ២០០៩ នៅសណ្ឋាគារអប្សរាអង្គរ ខេត្តសៀមរាប ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

-បានចូលរួមសិក្ខាសលាស្តីពីការពង្រឹងប្រសិទ្ធិភាពនៃភាពជាដៃគូរ នាថ្ងៃទី ០៩-១០ ខែកញ្ញា ឆ្នាំ២០០៩ នៅសណ្ឋាគារអង្គរសែនជូរី ខេត្តសៀមរាប ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**២-សន្និដ្ឋាន**

ក្នុងរយៈពេលប្រាំបួនខែ ឆ្នាំ២០០៩ នេះក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័នយុត្តិធម៌ ដោយមានអគ្គលេខាធិការដ្ឋានជា សេនាធិការបានសម្រេចនូវសមិទ្ធផលជាច្រើនមានជាអាទិ៍ ការកែសម្រួលរចនាសម័ន្ធ និងការពង្រឹងសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់ខ្លួន ការបន្តអនុវត្តនូវគម្រោងសំខាន់ៗមួយចំនួន ដូចជា គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា គម្រោងពង្រឹងអង្គភាពនីតិកម្ម គម្រោងតុលាការគំរូ គម្រោងបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា និងគម្រោងតុលាការរដ្ឋបាល។

**៣-ទិសដៅអនុវត្តក្នុងត្រីមាសបន្ត ឆ្នាំ២០០៩**

- បន្តអនុវត្តគម្រោងតុលាការគំរូ
- បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ
- បន្តអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិនៅកម្ពុជាដោយសហការជាមួយ UNDP
- បញ្ចប់របាយការណ៍ស្តីពីប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា ដែលមានការសហការពី អទឈ
- បន្តអនុវត្តគម្រោងពង្រឹងអង្គភាពនីតិកម្ម

-បន្តសិក្សារៀបចំអនុក្រឹត្យស្តីពីរដ្ឋបាលតុលាការ

-បន្តសិក្សារៀបចំផែនការសកម្មភាពជំនួយផ្នែកច្បាប់

-បន្តជំរុញការអនុវត្តប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងកិច្ចសហប្រត្តិបត្តិការជាមួយ GTZ ជាពិសេសក្នុងការរៀបចំមូលដ្ឋានទិន្នន័យស្តីពីមុខងារ ស្ថាប័នរដ្ឋ

-បន្តពិភាក្សាជាមួយវិទ្យាស្ថានដាណឺម៉ាកសម្រាប់សិទ្ធមនុស្ស "DIHR" ក្នុងការជួយឧបត្ថម្ភដល់ការងាររបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែវិច្ឆិកាឆ្នាំ២០០៩

**អ្នកធ្វើរបាយការណ៍**

**ស៊ុន សិរីវុធ**

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**